Inform-សជណ/ 31-07-17/អ៊-បល-P.171

# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា

លេខ : ៧៤៦៨ [illegible]

## សេចក្តីជូនដំណឹង
## ស្តីពី ការជ្រើសរើសបុគ្គលិក

អគ្គិសនីកម្ពុជា សូមជម្រាបជូនដំណឹងដល់សាធារណៈជនថា អគ្គិសនីកម្ពុជា ត្រូវការជ្រើសរើស**បុគ្គលិក ចំនួន ១៨ រូប** ដើម្បីចូលបម្រើការងារនៅ អង្គភាពបណ្តាញបញ្ជូន នៃនាយកដ្ឋានបញ្ជូនអគ្គិសនី ដូចខាងក្រោម :

*- **<u>លក្ខណៈសម្បត្តិបេក្ខជន</u>** :

**១. បុគ្គលិកវាស់កំដៅនិងវេស៊ីស្តង់ដីខ្សែបញ្ជូន** ចំនួន ០១ រូប :

- បេក្ខជនភេទប្រុស,មានអាយុចាប់ពី ១៨ឆ្នាំ ដល់ ៣៥ឆ្នាំ
- បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធ E.III.១ ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន ៩០%
- កម្រិតជំនាញ : បញ្ចប់ការសិក្សា បរិញ្ញាបត្រវិស្វកម្មអគ្គិសនី ឡើងទៅ
- ចំណេះដឹងកុំព្យូទ័រ : Microsoft Word-Excel
- ភាសាអង់គ្លេស : ចេះអាចប្រើការបាន ជាមធ្យម ។

**២. បុគ្គលិកល្បាតខ្សែបញ្ជូនក្នុងរាជធានីភ្នំពេញ** ចំនួន ០៣រូប, **បុគ្គលិកល្បាតខ្សែបញ្ជូនតាមតំបន់** (អនុស្ថានីយទី៧-អនុស្ថានីកំពង់សឺង្គ ចំនួន ០៤ រូប និងអនុស្ថានីយកំពង់សឺង្គ-អនុស្ថានីយច្រកម្ទេស ចំនួន ០៤ រូប), **បុគ្គលិកថែទាំនិងជួសជុលខ្សែបញ្ជូន 230KV** ចំនួន ០២ រូប, **បុគ្គលិកថែទាំនិងជួសជុលខ្សែបញ្ជូន 115KV** ចំនួន ០២ រូប, **បុគ្គលិកសុវត្ថិភាពការងារខ្សែបញ្ជូន** ចំនួន ០១ រូប និង**បុគ្គលិករោងជាងមេកានិកខ្សែបញ្ជូន** ចំនួន ០១ រូប ( សរុបចំនួន ១៧ រូប ) :

- បេក្ខជនភេទប្រុស,មានអាយុចាប់ពី ១៨ឆ្នាំ ដល់ ៣៥ឆ្នាំ
- បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធ E.III.១ ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន ៩០%
- កម្រិតជំនាញ : បញ្ចប់ការសិក្សា សញ្ញាប័ត្រមធ្យមបច្ចេកទេសអគ្គិសនី ឡើងទៅ
- ចំណេះដឹងកុំព្យូទ័រ : Microsoft Word-Excel
- ភាសាអង់គ្លេស : ចេះអាចប្រើការបាន ជាមធ្យម ។

*- **ពាក្យសុំចូលប្រឡងដើម្បីបម្រើការងារនៅអគ្គិសនីកម្ពុជាបេក្ខជនត្រូវទាញយក(Download) ដោយផ្ទាល់ពីក្នុងគេហទំព័ររបស់អគ្គិសនីកម្ពុជា គឺ : www.EDC.com.kh ត្រង់ចំណុចព័ត៌មានវិជ្ជាជីវៈ ដោយចុចលើពាក្យសុំចូលប្រឡងដើម្បីបម្រើការងារនៅ អគ្គិសនីកម្ពុជា។**

*- **<u>បេក្ខជនត្រូវមកដាក់ពាក្យ និង ភ្ជាប់មកជាមួយនូវ</u>** :

- ពាក្យសុំចូលប្រឡងដើម្បីបម្រើការងារ នៅអគ្គិសនីកម្ពុជា ចំនួន ០១ ច្បាប់
- ប្រវត្តិរូបសង្ខេប មានបិទរូបថត ៤ x ៦ ចំនួន ០១ ច្បាប់
- កិច្ចសន្យា សម្រាប់បំពេញពាក្យសុំចូលបម្រើការងារ និងកិច្ចសន្យាការងារ ចំនួន ០១ ច្បាប់
- សលាកប័ត្របេក្ខជន ចំនួន ០១ ច្បាប់
- ច្បាប់ចម្លងសញ្ញាប័ត្រចំណេះដឹងទូទៅ និងសញ្ញាប័ត្រជំនាញ ចំនួន ០១ ច្បាប់
- តារាងពិន្ទុ (TRANSCRIPT) ចំនួន ០១ ច្បាប់

អគ្គិសនីកម្ពុជា : # ២ ផ្លូវ ព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ    ទូរស័ព្ទ : ០២៣ ៧២៣ ៩៧១ - ៧២៤ ៧៧១    ទូរសារ : (៨៥៥) ២៣ ៤២៦ ០១៨

*- **ចំពោះបែបបទមួយចំនួនទៀត ដូចមានចែងក្នុងឧបសម្ព័ន្ធI នៃលក្ខន្តិកៈបុគ្គលិកអគ្គិសនីកម្ពុជា បេក្ខជនប្រឡងជាប់ មានកាតព្វកិច្ចបំពេញបន្ថែម ។**

*- **ទីកន្លែងទទួលពាក្យ** : **នៅអគារ B ជាន់ទី១ ការិយាល័យបុគ្គលិក នៃអគ្គិសនីកម្ពុជា**
ចាប់ពីថ្ងៃផ្សាយដំណឹងនេះ រហូតដល់ថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៧ រៀងរាល់ថ្ងៃធ្វើការ

- ពេលព្រឹក ចាប់ពីម៉ោង ០៨ : ០០ ដល់ម៉ោង ១១ : ៣០
- ពេលល្ងាច ចាប់ពីម៉ោង ១៤ : ០០ ដល់ម៉ោង ១៧ : ០០ ។

*- **ព័ត៌មានផ្សេងៗ** : សូមអញ្ជើញមកទាក់ទង ការិយាល័យរដ្ឋបាល ទីស្នាក់ការកណ្តាល អគ្គិសនីកម្ពុជា ឬតាមរយៈលេខទូរស័ព្ទ ០២៣ ៧២៣ ៩៧១ និង ០២៣ ៧២៤ ៧៧១ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១៧

ជ. **ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**
**ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា**
**អគ្គនាយករង**

ELECTRICITE DU CAMBODGE

**ចេង_គន្ធា**

**បញ្ជាក់**

- សេចក្តីជូនដំណឹងនេះ ធ្វើការផ្សព្វផ្សាយជាផ្លូវការតាមរយៈគេហទំព័ររបស់ អគ្គិសនីកម្ពុជា គឺ : www.EDC.com.kh ត្រង់ចំណុច " ព័ត៌មានវិជ្ជាជីវៈ " ។